**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:២៥៩
ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៩
**សាលដីកា**
លេខ:០៤
ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០១

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០១ ដោយមានសមាសភាពដូចតទៅ:
១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............... ជាចៅក្រមរបាយការណ៍
៣-លោក ............. ជាចៅក្រម
៤-លោក ............. ជាចៅក្រម
៥-លោក ............. ជាចៅក្រម

**ក្រឡាបញ្ជី**
-លោកស្រី ..............

**តំណាងមហាអយ្យការ**
-ឯកឧត្តម ............. ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ២១៥ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៦២៩ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍រវាង

-ដើមចោទឈ្មោះបង(ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ មុខរបររកស៊ីលក់ដូរ ទីលំនៅសព្វថ្ងៃ ភូមិមេម៉ាយ ឃុំបឹងកុក ស្រុកកំពង់ចាម ខេត្តកំពង់ចាម ។

ឪពុកឈ្មោះហុង ឈាង (រ) ម្តាយឈ្មោះអ៊ុយ ខេង(រ) ប្រពន្ធឈ្មោះយាប រី មានកូន៣នាក់ ។

ចុងចម្លើយឈ្មោះតឈឡ(ចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ ៤៦ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ទីលំនៅសព្វថ្ងៃ ភូមិបឹងកុក១ ឃុំបឹងកុក ស្រុកកំពង់ចាម ខេត្តកំពង់ចាម ។ ឪពុកឈ្មោះតៃ គិត(ស) ម្តាយឈ្មោះម៉ៅ លាយ(រ) ប្តីគ្មាន មានកូន០២នាក់ ។

**កម្មវត្ថុបណ្តឹង:** ប្តឹងទាមទាររថយន្តកាំម៉ាស់មួយគ្រឿង

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ២៥៩ចុះថ្ងៃទី១៥ខែកញ្ញាឆ្នាំ១៩៩៩របស់តុលាការកំពល

-បានឃើញបណ្តឹងសាទុក្ខលេខ១៣៨ ចុះថ្ងៃទី១៤-០៥-១៩៩៩ របស់លោកបងប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋវេណីលេខ២១៥ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៣-០៧-១៩៩៧ របស់ឈ្មោះបងប្តឹងសុំសិទ្ធិកាន់កាប់រថយន្តកាំម៉ាស់មួយគ្រឿងទាំងក្បាលទាំងរឺម៉ក់សណ្តោង ដែលឈ្មោះហាក់ យឹម និងប្រពន្ធឈ្មោះហ៊ូ នាង ដាក់បញ្ចាំឱ្យខ្លួនក្នុងចំនួន

២៥.០០០ដុល្លាអាមេរិក ពីឈ្មោះតឈឡដោយសំអាងហេតុថា ឈ្មោះតឈឡបានទិញរថយន្តនេះពីឈ្មោះហាក់ យឹម និងប្រពន្ធឈ្មោះហ៊ូ នាង ដែលអ្នកទាំងពីរនេះដាក់បញ្ចាំឱ្យខ្លួនតាំងពីថ្ងៃទី០៩-១២-១៩៩៦ ជាប្រាក់ចំនួន២៥.០០០ដុល្លាអាមេរិក ក្នុងចំនួនទឹកប្រាក់ខ្ចីពីខ្លួន៧៥.០០០ដុល្លា រថយន្តដាក់បញ្ចាំឱ្យខ្លួនលេខ យ-០០២១ ភព៣ លេខម៉ាស៊ីន០០២០៣៩១ លេខសាក់ស៊ី០៤៨៩ លេខតួ០៤៣០៧៥៧ ស្រាប់តែឃើញនៅលើដៃឈ្មោះតឈឡដោយមានធ្វើលិខិតអន្តរាគមន៍ខេត្តកំពង់ចាម ឱ្យប្រើប្រាស់ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១៣៨ (ក) ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ របស់តុលាការខេត្តកំពង់ចាម ដែលបានសម្រេចសេចក្តីដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះបងចុះថ្ងៃទី០៣-០៦-១៩៩៧ ដែលប្តឹងសុំសិទ្ធិកាន់កាប់រថយន្តកាម៉ាស់លេខ០០២១ ពីចុងចម្លើយឈ្មោះតឈឡទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។ (មិនស្របតាមមាត្រា៦៤ ក្រឹត្យច្បាប់លេខ៣៨ កិច្ចសន្យាស្តីពីការបញ្ចាំចលនវត្ថុ) ។

២-ទទួលពាក្យបណ្តឹងសារត្រឡប់របស់ចុងចម្លើយឈ្មោះតឈឡនៅពេលសវនាការសុំឲ្យតុលាការទទួលស្គាល់ខ្លួនជាម្ចាស់រថយន្តកាម៉ាស់លេខ០០២១ ភព៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ ។

៣-ទទួលស្គាល់ប័ណ្ណសំគាល់យានយន្ត ម៉ាកកាម៉ាស់ ប្រភេទដឹកទំនិញពាក់ផ្លាកលេខយ-០០២១ ចុះថ្ងៃទី០៩-០៥-៩៧ របស់ក្រសួងសាធារណៈការ និងដឹកជញ្ជូន ដែលមានម្ចាស់កម្មសិទ្ធិឈ្មោះតឈឡទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។ (តាមមាត្រា៤១ នៃក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យានៃការលក់) ។

៤-ចាប់ពីពេលនេះតទៅឈ្មោះតឈឡមានសិទ្ធិគ្រប់គ្រង ប្រើប្រាស់អាស្រ័យផលនិងចាត់ចែងលើរថយន្តកាម៉ាស់ពាក់ផ្លាកលេខយ-០០២១ ភព៣ លេខម៉ាស៊ីនប០២០៣៩១ លេខតួ០៤៣០៧៥៧ ទៅតាមច្បាប់កំណត់ ។

៥-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ៧.០០០រៀល ដែលដើមចោទបានបង់រួចហើយ នៅពេលដែលសាលក្រមចូលជាស្ថាពរបង្គាប់ឲ្យដើមចោទបង់ពន្ធសមាមាត្រ១%ស្មើ $\frac{1x25000\$}{100} = 2500\$$ =៧៥០០០០$ ដែលត្រូវដាក់ចូលថវិការដ្ឋ៨០% និង បានរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០% ។ ប្រាក់នេះឲ្យចុងចម្លើយបង់ជាមុនទើបបង្គាប់ឲ្យដើមចោទសងវិញជាក្រោយ ។

៦-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខដើមចោទ និងចុងចម្លើយ ភាគីណាមិនសុខចិត្ត មានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៦២ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៧ របស់ឈ្មោះបងប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ១៣៨(ក) ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ របស់តុលាការខេត្តកំពង់ចាម ត្រង់ចំណុចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីកាបៀបលេខ៣៨ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីដូចតទៅ :

បញ្ជូលឈ្មោះហាក់ យឹម អាយុ៥១ឆ្នាំ ទីលំនៅសព្វថ្ងៃផ្ទះលេខ១០ ផ្លូវលេខ១៨១០ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជាតតិយជនខាងចុងចម្លើយ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ២១៥ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៤-១០-១៩៩៧ របស់បងទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ១៣៨(ក) ចុះថ្ងៃទី២៣-៩-១៩៩៧ របស់តុលាខេត្តកំពង់ចាម ទុកជាបានការ ។

៣-សម្រេចកាត់យកប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥០០០៛ និងលើអាផ្ទាធរតុលាការ ៥០០០៛ ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី កំបាំងមុខតតិយជនឈ្មោះហាក់ យឹម បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ១៣៨ ចុះថ្ងៃទី១៤-០៥-១៩៩៩ របស់លោកបងប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ២១៥ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៩របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា ៖

-បណ្តឹងសាទុក្ខរបស់ដើមចោទ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។

-សាលដីការដ្ឋប្បវេណីលេខ២១៥ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិចារណាតាមច្បាប់តទៅ ។

-បានស្តាប់ចម្លើយរបស់ឈ្មោះបងនាពេលសវនាការថា៖ បានជាខ្លួនប្តឹងសាទុក្ខមកតុលាការកំពូល មកពីសាលាឧទ្ធរណ៍សម្រេចសេចក្តី មិនត្រឹមត្រូវឱ្យខ្លួន ព្រោះថា៖ តឈឡបានទិញរថយន្តពីឈ្មោះយឹម ហាក់ និងប្រពន្ធឈ្មោះហូ នាង ដែលដាក់បញ្ចាំឱ្យខ្លួនក្នុងចំនួនទឹកប្រាក់២៥.០០០ ដុល្លាអាមេរិក ក្នុងចំនួនទឹកប្រាក់៧៥.០០០ដុល្លាអាមេរិក តាំងពីថ្ងៃទី០៩-១២-១៩៩៦ ។ រឿងនេះខ្លួនបានដាក់ពាក្យបណ្តឹងទៅតុលាការខេត្តក្រចេះ តុលាការខេត្តក្រចេះ ក៏បានសំណុំរឿងនេះមកតុលាការខេត្តកំពង់ចាម ជាអ្នកដោះស្រាយវិញ ។ ព្រោះខ្លួនជាម្ចាស់បំណុលដូចគ្នា សុំឱ្យតុលាការកំពូល មេត្តាចែកប្រាក់នេះ ជាពីរចំណែកស្មើគ្នា ព្រោះយើងជាម្ចាស់បំណុលដូចគ្នា ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់លោកប៉ាក់ ង៉ាក់

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៣៨ ចុះថ្ងៃទី១៤-០៥-១៩៩៩ របស់លោកបងបានធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះ បានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់ និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា តុលាការថ្នាក់ក្រោមមុននឹងសម្រេចរឿងនេះ ដល់អង្គសេចក្តីបានធ្វើការស៊ើបសួរត្រឹមត្រូវតាមនីតិវិធីហើយ ។

-យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ចុងចម្លើយឈ្មោះតឈឡមានសិទ្ធិគ្រប់គ្រងប្រើប្រាស់អាស្រ័យផល និងចាត់ចែងលើរថយន្តកាម៉ាស់ពាក់ផ្លាកលេខយ-០០២១ភព៣ លេខម៉ាស៊ីន ០០២០៣៩១ លេខតួ ០៤៣០៧៥៧ ទៅតាមច្បាប់ ។ ហើយលោកបងពុំមានសិទ្ធិឡើងជាម្ចាស់នៃវត្ថុបញ្ចាំបានឡើយតាមមាត្រា៧១នៃក្រឹត្យច្បាប់លេខ៣៨ក្រចស្តីពីកិច្ចសន្យានឹងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

-យល់ឃើញថា ការលើកឡើងក្នុងសារណារបស់លោកបងសុទ្ធតែជារឿងនៃអង្គហេតុ ដែលតុលាការថ្នាក់ក្រោម បានពិចារណារួចហើយ ។

- យល់ឃើញថា អ្នកស្រីតឈឡពុំបានធ្វើសារណាការពាររឿងក្តីរបស់អ្នកស្រីជូនមកតុលាការកំពូលទេ ហើយក៏ពុំបានមកចូលរួមសវនាការនេះដែរ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះបាំងមុខអ្នកស្រី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ២១៥ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**ឧនិច្ឆ័យសេចក្តីចំពោះមុខលោកបងកំបាំងមុខ**

**អ្នកស្រីតឈឡប៉ុន្តែចាត់ ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ១៣៨ ចុះថ្ងៃទី១៤-០៥-១៩៩៩ របស់លោកប៉ាក់ ង៉ាក់ទុកជាត្រឹមត្រូវតាមទំម្រង់តាមច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ២១៥ ចុះថ្ងៃទី០៦-០៥-១៩៩៩ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛ ដែលលោកប៉ាក់ ងាក់បានបង់រួចហើយគឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ។
បង្គាប់ឱ្យដើមចោទបង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការខេត្តកំពង់ចាម ។
៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០០១ ។